ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

# សេចក្តីជូនដំណឹង

នៅពេលកន្លងទៅថ្មីៗនេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានទទួលព័ត៌មានអំពីភាពមិនប្រក្រតីក្នុងដំណើរការបំពេញបែបបទចូលបម្រើការងារនៃមន្ត្រីក្របខ័ណ្ឌថ្មីពាក់ព័ន្ធនឹងសេចក្តីជូនដំណឹងលេខ៣៩៣៦ កសក ចុះថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០១៦ របស់ក្រសួងកសិកម្ម រុក្ខា-ប្រមាញ់ និងនេសាទ ស្តីពីការប្រឡងជ្រើសរើសចូលបម្រើការងារក្នុងក្របខ័ណ្ឌក្រសួងកសិកម្ម រុក្ខា-ប្រមាញ់ និងនេសាទ ដែលបានចែងនៅក្នុងចំណុចទី១០ មានខ្លឹមសារជាអាទិ៍ថា "លិខិតថ្កោលទោស ត្រូវផ្តល់រយៈពេល១៥ថ្ងៃ ក្រោយពេលប្រកាសលទ្ធផលប្រឡងជាប់ ចំនួន១ច្បាប់"។

ករណីនេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សូមជម្រាបជូនដំណឹងដល់សិស្ស-និស្សិត ទាំងពីរភេទដែលទើបប្រឡងជាប់ជាស្ថាពរ នាសម័យប្រឡងថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០១៦ ជ្រាបថា ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ពុំបានកំណត់យកកម្រៃសេវាក្រៅផ្លូវការ លើការសម្របសម្រួលពន្យារពេលទទួលលិខិតថ្កោលទោសពីសិស្ស-និស្សិតទើបប្រឡងជាប់ឡើយ។ ប្រសិនបើមានភាពមិនប្រក្រតីណាមួយកើតឡើងពាក់ព័ន្ធនឹងការយកកម្រៃសេវាក្រៅផ្លូវការនេះ សូមសិស្ស-និស្សិត ទាំងពីរភេទទំនាក់ទំនង ឬ រាយការណ៍មកក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ជាបន្ទាន់តាមរយៈទូរស័ព្ទលេខ ០១២ ៨១៦ ៥៨១ ឬ ០១១ ៨១៨ ៧៩៨ ដើម្បីក្រសួងមានវិធានការតាមផ្លូវច្បាប់។

រាជធានីភ្នំពេញ, ថ្ងៃទី ២៧ ខែកញ្ញា ឆ្នាំ២០១៦

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

អាស័យដ្ឋានលេខ ២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា
ទូរស័ព្ទលេខ : (០២៣) ២១១ ៣៥១ / ២១១ ៣៥២ ទូរសារលេខ : (៨៥៥) ២៣-២១៧ ៣២០
Nº 200 Preah Norodom Sangkat Tonle Basak Khan Chamkarmon B V D Phnom Penh, Cambodia
Phone : (023) 211 351/211 352, Fax : (855) 23 - 217 320